សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ
ឆ្នាំទី ០២ លេខ ២៤៨ ចេញផ្សាយថ្ងៃ សៅរ៍ ទី ២០ ខែ កញ្ញា ឆ្នាំ ២០០៨

## ការគម្រាមប្តឹងមេដឹកនាំគណបក្សប្រឆាំងគឺជារឿងនយោបាយដើម្បីបំបិទមាត់
## ឡៅ ម៉ុងហៃ : ការប្តឹងមេបក្សប្រឆាំងនឹងនាំឱ្យមានការច្របូកច្របល់ថែមទៀត



លោក សម រង្ស៊ី មេដឹកនាំគណបក្សជំទាស់នៃប្រទេសកម្ពុជា



លោក ទេព នីថា



លោកបណ្ឌិត ឡៅ ម៉ុងហៃ



ទិដ្ឋភាពនៃការតវ៉ារបស់ប្រជាពលរដ្ឋដែលមិនបានបោះឆ្នោតកន្លងមក



រកឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញអន្តរាយរស់សង្ឃឹម

ដោយ : ៩.ឧត្តម

លោកសម រង្ស៊ីអ្នកតំណាងរាស្ត្រទើបជាប់ឆ្នោតថ្មីនៅមណ្ឌលកំពង់ចាម និងជាប្រធានគណបក្សសមរង្ស៊ី មិនបានសម្តែងនូវការតក់ស្លុតសូម្បីប៉ុនសរសៃសក់ឡើយ បើទោះបីជានាយករដ្ឋមន្ត្រីលោភអំណាចប្រឹងស្រែកគម្រាមតាមក្បាលមីក្រូថា នឹងប្តឹងលោក, ដកអភ័យឯកសិទ្ធិសភារបស់លោកក៏ដោយ ។

តទៅទំព័រ៤ ម

## សម្តេចឪព្រួយព្រះទ័យនឹងចោរសៀម ឈ្លានពានបូរណភាពទឹកដីនៃកម្ពុជា



សម្តេចឪ នរោត្តម សីហនុ



សកម្មភាពទាហានឈុតខ្មៅសៀមចូលឈ្លានពានទឹកដីកម្ពុជា

ដោយ : ស្សាវរីយ៍

ព្រះមហាវីរក្សត្រ ព្រះបាទ *នរោត្តម សីហនុ* សំដែងព្រះទ័យកង្វល់យ៉ាងខ្លាំង ទៅនឹងព័ត៌មាន ដែលថាទាហានឈុតខ្មៅសៀម ឈ្លានពានបូរណភាពទឹកដីខ្មែរ នៅតាមព្រំដែនភាគខាងលិច ហើយមេដឹកនាំ

តទៅទំព័រ២ ស

## អាចមានមូលហេតុធំពីរក្នុងការដែលរដ្ឋាភិបាលប្តឹងទៅក្រុមប្រឹក្សា សន្តិសុខអង្គការសហប្រជាជាតិរួចដកពាក្យបណ្តឹងមកវិញនោះ



លោក សុន ឆ័យ អ្នកនាំពាក្យគណបក្សសមរង្ស៊ី



លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីញៀននឹងអំណាចមិនស្កប់ស្កល់

ដោយ : គ.អរពិន្ទ

មន្ត្រីជាន់ខ្ពស់ នៃគណបក្សសមរង្ស៊ី បានថ្លែងនៅក្នុងបទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី ផ្សាយកាលពីម្សិលមិញកត់សម្គាល់នូវជំហរដកុរុញ រុញដករបស់គណបក្សប្រជាជន *ហ៊ុន សែន* រឿងទាហានសៀមលើកគ្នាចូលឈ្លានពានកាន់កាប់ដីខ្មែរ តាមបណ្តោយព្រំដែនដែលដំបូងរដ្ឋាភិបាលគណបក្សប្រជាជន

តទៅទំព័រ៤ ន

## មិន ឃិន ឃុបឃិតគ្នាបោកប្រាស់នាយករដ្ឋមន្ត្រី ក្នុងករណីលក់ដីសណ្ឋាគារណសិរ្ស



សណ្ឋាគាររណសិរ្សមើលចំពីមុខ



លោក មិន ឃិន

ដោយ : ទិសាល

មានសេចក្តីរាយការណ៍ព័ត៌មានមួយបានឱ្យយើងដឹងថា លោក *មិន ឃិន* រដ្ឋលេខាធិការក្រសួងធម្មការនិងជាអគ្គលេខាធិការគណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិបាន ឃុបឃិតផ្សំគំនិតគ្នាបោកប្រាស់

តទៅទំព័រ២ ខ

## នឹងមានចលនាប្រឆាំងស្ថានទូតសៀមនៅទូទាំងពិភពលោក

ដោយ : សច្ចះ

អ្នកស្នេហាជាតិខ្មែរ នៅប្រទេសអូទ្រីសម្នាក់ បានធ្វើការអំពាវនាវជាបន្ទាន់មួយ ស្នើឱ្យខ្មែរនៅក្នុងស្រុក និងនៅក្រៅប្រទេស ធ្វើមហាបាតុកម្មដ៏ធំមួយព្រមគ្នា នៅថ្ងៃទី១០ ខែ

តទៅទំព័រ៣ ឃ

## សុខ គង់ រំលោភយកដីវត្តសំពៅព្រៃលក្ខណ៍ ដើម្បីពង្រីកសណ្ឋាគារថ្នាក់ផ្កាយ៥នៅជ្រោយចង្វា



លោក កែប ជុតិមា



មេឈ្មួញ សុខ គង់ ថៅកែក្រុមហ៊ុនសុខាម៉ិច

ដោយ : គ.រដ្ឋា

នៅពេលដែលពួកអ្នកមានលុយ និងពួកអ្នកមានអំណាចឆ្ពាញ់នឹងការអភិវឌ្ឍន៍ជ្រុលពេកទៅ សូម្បីតែបំពានទៅលើដីបរិវេណវត្តអារាមដែលជាទីគោរពសក្ការៈរបស់ពុទ្ធសាសនិកជនខ្មែរ និងព្រះសង្ឃនោះ ក៏ពួកគេ

តទៅទំព័រ៣ ជ

## ស្រែកម្ហូយរ៉ាសចុះថ្លៃបាន១០០រៀលដែរ

ដោយ : រតនះ

លោកនាយករដ្ឋមន្ត្រី *ហ៊ុន សែន* កាលពីថ្ងៃទី១៥ ខែកញ្ញា ២០០៨ បានបញ្ជាឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់លោក*គាត ឈន់* ពិភាក្សាធ្វើការបញ្ចុះតម្លៃប្រេងសាំង ឱ្យស្រប ទៅនឹងទីផ្សារប្រេងឆៅ

តទៅទំព័រ២ គ



ស្ថានីយ៍ប្រេងឥន្ធនៈមួយកន្លែងក្នុងទីក្រុងភ្នំពេញ

ដំណឹងលក់ដីឡូត៍

យើងខ្ញុំមានដីឡូត៍លក់ ទំហំ 5m x 14m តម្លៃ 3600$ និងទំហំ 4.50m x 14m តម្លៃ 2700$ ផ្លូវ៧ម៉ែត្រ ក្រាលគ្រួសក្រហម ដែលមានទីតាំងស្ថិតនៅភូមិ ត្រពាំងប្រុយ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល (ជាប់របងរោងចក្រ ចូលតាមច្រក ផ្សារបែកចាន)។

សូមទំនាក់ទំនងទូរស័ព្ទលេខ : 012 920 500 , 011 73 62 77

ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្ទំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បើត ព្យាបាល យ៉ាងស័ក្តិសិទ្ធិ។

- មានបន្ទប់បុរស ស្ត្រី ដាច់ដោយឡែកពីគ្នា
- មានលក់ថ្នាំសម្រាប់ព្យាបាលដោយខ្លួនឯង

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្ពានចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : 012 363 331, 016 719 616,

*បរិយាយថ្ងៃនេះ*

## គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ

ដោយ : មាឌ្យ ច្រាផ្លា

កាលពីពេលថ្មីៗនេះ អ្នកនយោបាយជាន់ខ្ពស់របស់គណបក្សប្រជាជន ជាម យៀប ដែលជាសេដ្ឋីលើភាពក្រីក្ររបស់ប្រជារាស្ត្រខ្មែរនោះ បាននិយាយការពារនូវគំនិតនៃរបស់ដែលហៅថា ការបង្កើនបំប៉ែកតំណែងកៅអីមន្ត្រីរដ្ឋាភិបាលប្រទេសកម្ពុជាដ៏ក្រីក្រឱ្យមានចំនួនច្រើននោះ គឺជាការបង្កើនទិន្នផលការងារល្អទៅវិញសម្រាប់ប្រទេសជាតិ។

តទៅទំព័រ៤ ក

**តមកពីទំព័រ១ ខ**

លោក *ហ៊ុន សែន* ក្នុងរឿងលក់ដីសណ្ឋាគាររណសិរ្សហើយ ។

ក្នុងកិច្ចសន្យាលេខ០១៨ ឆ្នាំ២០០១ក.ជ.រ.ស ចុះថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ២០០១ ត្រង់ប្រការ១០២បញ្ជាក់ថា រយៈពេលជួល៤៩ឆ្នាំ (មុនសល់ ១២+៣៧) គិតពីថ្ងៃទី០១ មេសា ២០០១ ដល់ថ្ងៃ៣០ មេសា ឆ្នាំ២០៥០ នេះបញ្ជាក់ច្បាស់ថា សណ្ឋាគាររណសិរ្សនេះមានកិច្ចសន្យាជួលដោយអ្នកស្រី *គីម ចន្ថា* ដែលមានសុពលភាពរហូតដល់ឆ្នាំ២០៥០ ឯណោះ ។

អាក្រក់អាក្រីជាងនេះទៀត ដែលនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ត្រូវតែដឹង និងមានវិធានការទប់ស្កាត់ជាបន្ទាន់នោះ គឺលោក *មិន ឃិន* ដ៏មហិមាម្នាក់នេះ បានផ្តល់លុយដល់បុគ្គលិកគណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិក្នុងម្នាក់៧ពី២០០ ទៅ ៣០០ដុល្លារជាថ្នូរនឹងការដើរចេញពីទីតាំងសណ្ឋាគាររណសិរ្ស និងគណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិ ។

មិនតែប៉ុណ្ណោះលោក *មិន ឃិន* បាននិយាយតាមរបៀបគម្រាមថា បើបុគ្គលិកណាមិនយកលុយ គឺស្មើនឹងមានន័យថាប្រឆាំងជាមួយលោកនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ដែរ ។

ដោយសារលោក *មិន ឃិន* មានគំនិតមិនសូវល្អបែបនេះហើយ ទើបធ្វើឱ្យបុគ្គលិកមួយចំនួនធំបញ្ចេញប្រតិកម្មតវ៉ា ហើយចង់ដុតកង់ឡានបះបោរជាចំហតែម្តង ។ ប៉ុន្តែនៅពេលដែលលោក *មិន ឃិន* ដឹងថា ធុំក្លិនមិនសូវស្រួល ក៏យកលុយពី ២០០ ទៅ៣០០ដុល្លារទៅចែកឱ្យបុគ្គលិកម្នាក់៧ដើម្បីបិទមាត់កុំឱ្យបែករឿងខ្លាចដឹងដល់នាយករដ្ឋមន្ត្រី *ហ៊ុន សែន* ។

ទោះជាដូច្នេះក្តី ក៏បុគ្គលិកទាំងអស់នោះមិនបានស្ងប់ចិត្តដែរ ហើយពេលនេះពួកគេក៏ចាប់ផ្តើមតវ៉ាសាជាថ្មីម្តងទៀត ពោលគឺម្នាក់៧ព្យាយាមទាមទារច្រើនលើសពីចំនួន២០០ ទៅ៣០០ដុល្លារនេះ ។

ស្ថិតនៅក្នុងស្ថានភាពចម្រូងចម្រាស់រវាងបុគ្គលិកនិងលោក *មិន ឃិន* ដូច្នេះ គេជឿថា លោក *មិន ឃិន* ប្រាកដជាមិនចុះញ៉មនឹងបុគ្គលិកទាំងនោះទេ ព្រោះគេដឹង និងស្គាល់លោក *មិន ឃិន* យ៉ាងច្បាស់ថា លោកជាជនផ្តាច់ការម្នាក់ដែលមានឥទ្ធិពលមិនធម្មតាឡើយ ។

តាមពិតទៅបើយោងតាមខ្លឹមសារនៃកិច្ចសន្យាស្តីពីការជួលបន្ត និងគ្រប់គ្រងអាជីវកម្មបន្ទប់សណ្ឋាគាររណសិរ្សត្រង់ប្រការ០៨ បានចែងយ៉ាងជាក់លាក់ថា "*ពេលចប់កិច្ចសន្យានេះ ភាគី (ខ) អាចស្នើសុំបន្តធ្វើអាជីវកម្មតទៅទៀត លុះត្រាតែមានការឯកភាពពីភាគី (ក) ។ហើយភាគី (ខ) ជាភាគីទីមួយដែលមានអាទិភាពមុនគេក្នុងការបន្តធ្វើអាជីវកម្ម*" ។

ត្រង់ប្រការ០៩ នៃកិច្ចសន្យាដដែលនេះបានចែងថា "*ភាគី (ខ) មិនយកអគារនេះទៅជួល ឬផ្ទេរទៅភាគីដទៃទៀតដោយគ្មានការឯកភាព ពីភាគី (ក) ឡើយ ។ ភាគី (ក) មិនលក់ប្តូរឈ្មោះ ឬប្រគល់ទ្រព្យសម្បត្តិនេះទៅឱ្យភាគីទី៣ ដោយគ្មានការឯកភាពពីភាគី (ខ) ឡើយ*" ។

គួរបញ្ជាក់ថា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិរណសិរ្សតំណាងដោយលោក *ញ៉ែម វ៉ាលី* , លោក *ជា គាន* និង លោក *ជា សុខុម* ជាភាគី (ក) ។ ចំណែកអ្នកស្រី *គីម ចន្ថា* ប្រធានក្រុមហ៊ុនអមរិន្ទជាភាគី (ខ) ហើយកិច្ចសន្យានេះត្រូវបានធ្វើឡើងកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ ដោយមានការទទួលស្គាល់ពីលោក *មិន ឃិន* ផងដែរ ។

ប្រភពផ្តល់ព័ត៌មានបានបង្ហើបឱ្យដឹងថា ក្នុងនាមជាភាគី (ខ) អ្នកស្រី *គីម ចន្ថា* បានជួយថែរក្សា និងជួសជុលអគារសណ្ឋាគាររណសិរ្សនោះ ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុតព្រោះអ្នកស្រីបានចាត់ទុកថា សណ្ឋាគារនេះជាទ្រព្យសម្បត្តិរបស់រដ្ឋ ដែលត្រូវតែថែរក្សាឱ្យនៅគង់វង្ស ។

យ៉ាងណាក៏ដោយគេបានមើលឃើញថា លោក *មិន ឃិន* និងបរិវារមួយក្តាប់តូចដែលជាភាគី (ក) បានបំពានលើកិច្ចសន្យាយ៉ាងកម្រោលព្រោះនៅពេលពន្យារកិច្ចសន្យាម្តង៧ គឺត្រូវបង់លុយក្រៅ ។ ហើយការបង់ប្រចាំខែ ប្រចាំឆ្នាំ ក៏មានលុយក្រៅដែរ ។

ម្យ៉ាងទៀតលោក *មិន ឃិន* ក៏បានបំពានទៅនឹងគោលការណ៍របស់លោក *ហ៊ុន សែន* ដែលថា "*អាទិភាពមុនគេ គឺអ្នកមានកិច្ចសន្យាក្នុងការទិញ ឬជួលបន្តទៀត*" ។

ទន្ទឹមនេះគេបានព្រលយឱ្យយើងដឹងថា ប្រការដែលនាំឱ្យលោក *មិន ឃិន* លក់ដីសណ្ឋាគាររណសិរ្សនេះបាន គឺដោយសារគាត់បានលាក់កិច្ចសន្យាជួលជាមួយអ្នកស្រី *គីម ចន្ថា* មិនឱ្យថ្នាក់ដឹកនាំរណសិរ្សទាំងអស់ដឹង ។ហើយឥឡូវនេះទៀតសោតលោក *មិន ឃិន* ដ៏មហិមាកំពុងរិះរកគ្រប់មធ្យោបាយដើម្បីរំលាយកិច្ចសន្យាជួលសណ្ឋាគាររណសិរ្សនេះចោល និងធ្វើយ៉ាងណាឱ្យការលក់ដីនេះមានលក្ខណៈរលូនទៅតាមការចង់បានរបស់លោក *មិន ឃិន* ហើយ ។

តាមពិតទៅអ្នកដែលទិញដីសណ្ឋាគាររណសិរ្ស និងអគារអគ្គលេខាធិការដ្ឋានគណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិនេះ គឺជាកូនស្រីយាយភូឈ្មោះអ្នកស្រី *ជឹង សុគន្ធាវី* ។ ព្រោះកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨កន្លងទៅនេះ លោក *ជា សុទ្ធ* ដែលជាប្រធានគណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាបានចេញសេចក្តីជូនដំណឹងមួយស្តីពីការប្រគល់ទីតាំងផ្ទះលេខ៤០ ផ្លូវសុធារស សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ និងផ្ទះលេខ១៥០ (អតីតផ្ទះលេខ១៥៨) មហាវិថីនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមនក្រុងភ្នំពេញ ជូនទៅអ្នកស្រី *ជឹង សុគន្ធាវី* ។

ប៉ុន្តែការធ្វើបែបនេះគឺខុសពីគោលការណ៍របស់នាយករដ្ឋមន្ត្រីដែលកំពុងកៀងគរអ្នកវិនិយោគបរទេសឱ្យមករកស៊ីស្រុកខ្មែរ ចុះបើគេនាំគ្នាបំពានកិច្ចសន្យាបែបនេះជាហេតុការណ៍ដ៏អាក្រក់មួយធ្វើឱ្យអ្នកវិនិយោគដទៃទៀតគេមិនហ៊ានមករកស៊ីនៅក្នុងស្រុកខ្មែរទេ ។

ប្រសិនបើយើងមិនច្រឡំទេ នាយករដ្ឋមន្ត្រី *ហ៊ុន សែន* ធ្លាប់បានប្រកាសថា "*មុននឹងលក់ត្រូវចប់កិច្ចសន្យាជាមុនសិន*" ។ បានន័យថា ការសម្រេចចិត្តរបស់លោក *មិន ឃិន* នៅពេលនេះ គឺសាហាវណាស់ ៕

**តមកពីទំព័រ១ គ**

នៅលើពិភពលោក ។ សម្តីប្រមុខរដ្ឋាភិបាលនេះ បានធ្វើឱ្យមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភាក្សាជាមួយតំណាងក្រុមហ៊ុននានា នៅទីក្រុងភ្នំពេញ កាលពីថ្ងៃម្សិលមិញ ។

ក្រោយពីលោក *ហ៊ុន សែន* បានស្នើជាសាធារណៈ អោយក្រុមហ៊ុន និងក្រសួងសេដ្ឋកិច្ចពិភាក្សាបញ្ចុះតម្លៃនេះ តម្លៃប្រេងសាំងនៅតាមស្ថានីយ៍ខ្លះបានចុះថ្លៃ ១០០រៀលហើយក្នុងមួយលីត្រ គឺទៅតាមក្រុមហ៊ុន ។ ក្រុមហ៊ុនខ្លះ បានបញ្ចុះតម្លៃពី៥.២០០មកនៅត្រឹមតែ ៥.១០០រៀល ក្នុងមួយលីត្រ និងក្រុមហ៊ុនខ្លះទៀត បានចុះថ្លៃទី៥.១០០ មកនៅត្រឹមតែ ៥.០០០រៀលប៉ុណ្ណោះ នៅក្នុងមួយលីត្រកាលពីថ្ងៃព្រហស្បតិ៍ម្សិលម៉្ងៃ ។ ដូច្នេះសម្រែកប្រមុខរដ្ឋាភិបាលមួយវ៉ាស បញ្ចុះតម្លៃបាន១០០រៀល, ហើយបើសិនជាគាត់ ស្រែក១០វ៉ាសទៀត អាចនឹងបញ្ចុះតម្លៃបាន ១.០០០រៀលទៀត ។

តម្លៃប្រេងសាំង លើទីផ្សារពិភពលោកបានចុះថ្លៃ រហូតដល់ទៅ៤០%ហើយ តែលោក *ហ៊ុន សែន* អះអាងថាទីផ្សារពិភពលោក ចុះត្រឹមតែ២៥% ប៉ុណ្ណោះ ហើយកម្ពុជាវិញទើបតែចុះ១០%ប៉ុណ្ណោះ ។

តម្លៃប្រេងឆៅ នៅទីក្រុងញូវយ៉ក កាលពីថ្ងៃទី១៨ ខែកញ្ញា ២០០៨ បានធ្លាក់មកនៅត្រឹម៩៦ដុល្លារប៉ុណ្ណោះ គឺចុះថ្លៃប្រមាណ៤០%ដែលកាលពីប៉ុន្មានខែមុន តម្លៃជាង១៤៨ ដុល្លារក្នុងមួយធុង ឬក្នុងមួយបារ៉ែល ។ ការចុះតម្លៃនៅលើទីផ្សារពិភពលោកយ៉ាងគំហុកនេះ បែរជាទីផ្សារនៅកម្ពុជាចុះថ្លៃតិចតួចបំផុត គឺមិនដល់ ១០%ផង ដែលជាបញ្ហាមួយដ៏លំបាក សម្រាប់ប្រជាពលរដ្ឋខ្មែរ ។

កាលពីប្រេងសាំង ឡើងថ្លៃកាលពីប៉ុន្មានខែមុនលោក *គាត ឈន់* បានព្យាយាមបិទបាំងនូវទង្វើអសមត្ថភាព របស់រដ្ឋាភិបាលថា បណ្តាលមកពីទីផ្សារពិភពលោកថ្លៃដែរ, ហើយបើមានអ្នកណា ចង់ឱ្យប្រេងសាំងនៅកម្ពុជាចុះថោក ត្រូវនាំគ្នាទៅតវ៉ាជាមួយអង្គការ OPEC ទៅចុះ ។ ជាមួយគ្នានោះដែរ លោក *គាត ឈន់* ក៏បានថ្លែងថា រាជរដ្ឋាភិបាលបានចំណាយថវិកាជាតិរាប់លានដុល្លារ ជាសម្ងាត់ដើម្បីទប់តម្លៃទីផ្សារ ។ ប៉ុន្តែនៅពេល តម្លៃប្រេងសាំងនៅលើទីផ្សារពិភពលោក បានចុះយ៉ាងគំហុក ចំនួនប៉ុន្មានខែមកហើយនេះ, ហេតុអ្វីលោក *គាត ឈន់* មិនព្រមបញ្ចុះ ឬមួយរួមដៃគ្នាជាមួយក្រុមហ៊ុនពុករលួយជាសម្ងាត់ ដូចគាត់ធ្លាប់និយាយ ។

លោក *សុន ឆ័យ* សមាជិកសភាមណ្ឌលភ្នំពេញនិងជាអ្នកនាំពាក្យ គណបក្សសម រង្ស៊ី បានប្រាប់ *ខ្មែរម្ចាស់ស្រុក* កាលពីប៉ុន្មានថ្ងៃនេះថា "*យើងមានការព្រួយបារម្ភនិងមិនសប្បាយចិត្ត ចំពោះស្ថានភាព អំពីតម្លៃប្រេង ដូចបងប្អូនជនរួមជាតិយើងដូច្នោះដែរ ។ យើងបានឃើញថាតម្លៃប្រេងនៅកម្ពុជាដែលបានឡើងថ្លៃ រហូតដល់ ៥.៧០០រៀល ក្នុងមួយលីត្រនោះនៅពេលដែលតម្លៃប្រេងលើទីផ្សារអន្តរជាតិ ឡើងដល់ ១៤៨ដុល្លារក្នុងមួយធុង ។ តែឥឡូវនេះ តម្លៃប្រេងធ្លាក់មកនៅក្រោម ១០០ដុល្លារហើយ ក្នុងមួយធុង គឺបានន័យថាធ្លាក់តម្លៃមួយភាគបីហើយ*" ។

លោក *សុន ឆ័យ* បានថ្លែងថា បើតាមតម្លៃទីផ្សារសេរីគឺទីផ្សារប្រេងនៅប្រទេសកម្ពុជាត្រូវតែបញ្ចុះតម្លៃ អោយនៅយ៉ាងខ្ពស់បំផុត ៣.៨០០រៀលក្នុងមួយលីត្រ ។ លោកបានបន្តថា រដ្ឋាភិបាលនិយាយគ្មានការពិតទេ ដែលកន្លងទៅមន្ត្រីរដ្ឋាភិបាលនិយាយថា មិនអាចទប់តម្លៃប្រេងឡើងថ្លៃបានទេ ពីព្រោះការឡើងនេះគឺឡើងតាមតម្លៃទីផ្សារអន្តរជាតិ ។ ប៉ុន្តែឥឡូវ ទីផ្សារអន្តរជាតិ បានចុះមួយភាគបីហើយ ហេតុអ្វីបានជាទីផ្សារនៅកម្ពុជា មិនព្រមចុះថ្លៃ ដែលនេះជាការកេងប្រវ័ញ្ច និងហុតឈាមប្រជាពលរដ្ឋខ្មែរ ។ លោក *សុន ឆ័យ* បានមានប្រសាសន៍ថា ក្រុមហ៊ុនប្រេងនៅកម្ពុជា ដូចជាក្រុមហ៊ុនសូគីម៉ិចជាដើម គឺគេបានទិញប្រេងស្តុកទុកច្រើន ដែលគេទិញនោះ តាំងពីនៅតម្លៃថោកប៉ុន្តែគេតម្លើងថ្លៃភ្លាមឱ្យស្រប តាមទីផ្សារពិភពលោកដែរ, តែនៅពេលទីផ្សារពិភពលោកចុះថ្លៃមកវិញ គេមិនចុះទេ ដោយគេយកលេសថា គេទិញស្តុកទុកនោះ កាលពីនៅថ្លៃ ។

លោក *សុន ឆ័យ* បានរិះគន់រដ្ឋាភិបាលថា មិនបានពិនិត្យឱ្យបានត្រឹមត្រូវ ចំពោះការលក់

**តទៅទំព័រ៣ គ**

**តមកពីទំព័រ១ ស**

ខ្មែរលោក *ហ៊ុន សែន* ដែលជាបុរសខ្លាំង នៃប្រទេសកម្ពុជាកំសាក ដោយគ្រាន់តែនិយាយថា អត់ធ្មត់ឱ្យបានខ្ពស់បំផុតបើទោះបីជាចោរសៀម រំលោភបូរណភាពទឹកដី ជាបន្តបន្ទាប់ និងមើលងាយខ្មែរ យ៉ាងណាក៏ដោយ ។

ប្រភពដែលស្និទ្ធ នឹងមន្ត្រីម្នាក់នៃព្រះបរមរាជវាំងបានឱ្យដឹងថា សម្តេចឪបានបង្ហាញនូវកង្វល់យ៉ាងខ្លាំង បើទោះបីជាព្រះអង្គកំពុងសម្រាកព្យាបាលព្រះរោគ នៅប្រទេសចិនយ៉ាងណាក៏ដោយ ។ ជាមួយគ្នានោះដែរ សម្តេចឪបានបង្ហាញ នូវភាពមិនប្រក្រតីមួយ ដែលមិនធ្លាប់មាន នាពេលកន្លងមក គឺមិនឆ្លើយតប ទៅនឹងសំណើរបស់គណបក្សសម រង្ស៊ី ដែលយាងព្រះអង្គ ឱ្យដឹកនាំការរកដំណោះស្រាយ ជាមួយសៀមដែលបំពុងបន្តឈ្លានពានបូរណភាពទឹកដីខ្មែរ រយៈពេលជាង ២ខែនេះ ។ មន្ត្រីរូបនោះបានឱ្យដឹងទៀតថា សម្តេចឪកំពុងយកព្រះទ័យទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាទំនាស់ព្រំដែន ជាមួយប្រទេសសៀមនេះ ។

លោក *សម រង្ស៊ី* ប្រធានគណបក្សសម រង្ស៊ី កាលពីថ្ងៃទី០២ កញ្ញា ២០០៨ បានសរសេរលិខិត ស្នើសម្តេចឪ ព្រះ *នរោត្តម សីហនុ* អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ធ្វើព្រះរាជអន្តរាគមន៍ករណី ទាហានឈុតខ្មៅសៀមឈ្លានពានបូរណភាពទឹកដីខ្មែរជាច្រើនកន្លែង តាមបណ្តោយព្រំដែនភាគខាងលិច ។

មន្ត្រីព្រះបរមរាជវាំង បានប្រាប់ *ខ្មែរម្ចាស់ស្រុក* កាលពីថ្ងៃម្សិលមិញសុំមិនឱ្យបញ្ចេញឈ្មោះថា បើតាមការអោយដឹងពីប្រទេសចិនសម្តេចឪទំនងជាមិនប្រកែកអ្វីទេ ចំពោះការស្នើសុំរបស់គណបក្សសម រង្ស៊ី បើសិនជាសំណើនោះ មានការឯកភាព ពីរាជរដ្ឋាភិបាលខ្មែរ ពិសេសពីលោក *ហ៊ុន សែន* ។ មន្ត្រីដដែល បានឱ្យដឹងទៀតថា តាមទម្លាប់ នាពេលកន្លងមក បើសិនជាសម្តេចឪ មិនទទួលយកការស្នើសុំ ធ្វើព្រះរាជអន្តរាគមន៍ ពីនរណាមួយ ព្រះអង្គតែងតែឆ្លើយតបដោយបញ្ជាក់ថា សំណើនោះបានបញ្ជូនទៅលោក *ហ៊ុន សែន* ទៅស្ថាប័នពាក់ព័ន្ធហើយ គឺព្រះអង្គគ្មានអំណាចទេ ។ មានពេលខ្លះព្រះអង្គ ក៏បានបញ្ជាក់ផងដែរថា ព្រះអង្គ ស្ថិតនៅជាអព្យាក្រឹត មិនកាន់អំណាចទេ រាល់ការងារទាំងអស់មានតែរដ្ឋាភិបាលប៉ុណ្ណោះជាអ្នកដោះស្រាយ ។

លិខិតរបស់លោក *សម រង្ស៊ី* នេះ បានត្រូវចំអកឱ្យ ដោយលោក *ខៀវ កាញារីទ្ធ* រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាអ្នកនាំពាក្យគណបក្សប្រជាជនថា ជាការកេងចំណេញ ផ្នែកនយោបាយប៉ុណ្ណោះ ។ ប៉ុន្តែសម្រាប់ក្រុមអ្នកច្បាប់ ពិសេសព្រឹទ្ធបុរសខ្មែរ ដែលជាមន្ត្រីរាជការក្នុងរបបសង្គមរាស្ត្រនិយមបានអះអាងថា សម្តេចឪធ្លាប់មានបទពិសោធន៍ ការងារព្រំដែន និងឈ្នះក្តីជាមួយសៀម ករណីប្រាសាទព្រះវិហារ ។

ពិភពលោកបានដឹងឮថាពួកចោរសៀម បានឈ្លានពានខ្មែរ យ៉ាងងងើល ដែលអំពើនេះគួរតែកម្ពុជាប្តឹងទៅ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឱ្យដោះស្រាយ ។ ផ្ទុយទៅវិញ រដ្ឋាភិបាល បានជ្រើសរើសយកការចរចានេះបានធ្វើអោយអ្នកស្នេហាជាតិខ្មែររិះគន់ថា នឹងមិនអាច យកឈ្នះសៀមបានទេ គឺទាំងផ្នែកនយោបាយនិងផ្នែកយោធា ពីព្រោះទាហានខ្មែរពាក់ស្បែកជើងផ្ទាត់និងមេទ័ពខ្មែរសព្វថ្ងៃ មិនមែនជាពូជមាន់ជល់ហើយជាមាន់គ្រាវតែប៉ុណ្ណោះ ។ ម្យ៉ាងមេទ័ពខ្មែរខ្លះដុះក្បាលពោះអស់ហើយគឺមិនអាចដឹកនាំទ័ព ការពារទឹកដីបានទេ, តែពួកនេះមានសមត្ថភាព ដឹកនាំកម្លាំងយោធា ធ្វើបាបប្រជាពលរដ្ឋនិងប្លន់ដីធ្លីប្រជាពលរដ្ឋ ។

រដ្ឋាភិបាល បានធ្វើការចរចាជាមួយសៀម ជាច្រើនដងមកហើយ គឺថ្នាក់មេបញ្ជាការកងទ័ព, ថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេស ដែលបានប្រព្រឹត្តទៅនៅខ្មែរម្តង នៅសៀមម្តង និងរវាងនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ជាមួយ អតីតនាយករដ្ឋមន្ត្រីសៀម *សាម៉ាក់ ស៊ុនដារ៉ាវ៉េត* តាមទូរស័ព្ទ ។ប៉ុន្តែឥឡូវសៀមបានប្តូរ នាយករដ្ឋមន្ត្រីថ្មីហើយ គឺលោក *ស៊ុមឆៃ វង់សាវ៉ាត* ហើយលោក *ហ៊ុន សែន* បានស្នើឱ្យមានការចរចា ជាមួយចោរសៀម ឱ្យបានឆាប់រហ័សបំផុត ។

គួរបញ្ជាក់ថា ទាហានឈុតខ្មៅសៀម បានឈ្លានពានចូលបូរណភាពទឹកដីខ្មែរ ជាងពីរខែហើយ ដែលជំហានដំបូងគឺនៅតំបន់ ក្បែរប្រាសាទព្រះវិហារ, ប្រាសាទតាមាន់ធំ ជប់គគីរ និងតំបន់មួយចំនួន នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យជាដើម ។

ដោយឃើញរដ្ឋាភិបាលគ្មានសមត្ថភាពក្នុងការដោះស្រាយបញ្ហាជាមួយចោរសៀម និងបើកដៃឱ្យសៀម បន្តចូលនៅតាមតំបន់មួយចំនួនទៀតនោះ បានធ្វើឱ្យ អ្នកស្នេហាជាតិខ្មែរពិតប្រាកដ ពិសេសលោក *សម រង្ស៊ី* និងថ្នាក់ដឹកនាំ គណបក្សសម រង្ស៊ី បានសរសេរលិខិតជាផ្លូវការ ស្នើទៅសម្តេចឪ ឱ្យជួយធ្វើព្រះរាជអន្តរាគមន៍ ជាបន្ទាន់ដើម្បីការពារបូរណភាពទឹកដីខ្មែរ ។ ស្របពេលដែលលិខិតរបស់គណបក្សសម រង្ស៊ី ស្នើសម្តេចឪ អោយធ្វើព្រះរាជអន្តរាគមន៍នេះប្រភពដែលស្និទ្ធនឹងព្រះបរមរាជវាំង បានឱ្យដឹងថាសម្តេចឪសំដែងព្រះទ័យព្រួយបារម្ភយ៉ាងខ្លាំង ទៅនឹងព័ត៌មានដែលថា ទាហានឈុតខ្មៅ និងប៉ារ៉ាសៀម បន្តឈ្លានពានចូលក្នុងដីខ្មែរជាបន្តបន្ទាប់ ពិសេសនៅច្រកជាំស្រងាំ និងប្រាសាទតាក្របីនៅក្នុងអាណាចក្រឧត្តរមានជ័យជាដើម ។ ជាមួយគ្នានោះដែរ គេសន្និដ្ឋានថា សម្តេចឪ សព្វព្រះទ័យក្នុងកាដឹកនាំដោះស្រាយបញ្ហា ជាមួយនឹងសៀមទៅតាមការស្នើសុំរបស់គណបក្សសម រង្ស៊ី នាពេលថ្មីៗនេះថែមទៀតផង ៕

**តមកពីទំព័រ១ ម**

មេដឹកនាំគណបក្សប្រឆាំងដ៏ល្បីល្បាញរូបនេះបានមានប្រសាសន៍ឱ្យបណ្ដាញព័ត៌មានដឹងថា ការគម្រាមប្ដឹងប្រឆាំងនឹងរូបលោកក្នុងពេលនេះ គឺជារឿងនយោបាយសុទ្ធសាធ ។ ហើយក៏មានគោលដៅបំបិទមាត់លោកមិនឱ្យតវ៉ានឹងការបោះឆ្នោតដ៏មហាអយុត្តិធម៌នេះតទៅទៀតដែរ ។

លោក *សម រង្ស៊ី* បានសង្កត់ធ្ងន់ថា "*ការគម្រាមបែបហ្នឹងមិនបានធ្វើឱ្យខ្ញុំមានការភ័យខ្លាចអ្វីទាល់តែសោះ ។ ហើយក៏មិនបានធ្វើឱ្យខ្ញុំបញ្ឈប់សកម្មភាពគណបក្សប្រឆាំងដែរ* " ។

លោកបានបន្តទៀតថា "*ការចោទប្រកាន់នោះអត់មានមូលដ្ឋានទេ ព្រោះសភាថ្មីនេះមិនទាន់កើតឯណា ? ហើយអ្វីដែលខ្ញុំនិយាយនេះ គឺខ្ញុំនិយាយតាំងពីពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោតបន្តិច ។អញ្ចឹងទេតើអ្នកណាទៅប្ដឹងក្នុងនាមសភានៅពេលដែលសភាហ្នឹងមិនទាន់ទាំងចេញជារូបរាងផង*"?

គួររំលឹកថា នាយករដ្ឋមន្ត្រីញៀននឹងអំណាចឈ្មោះ *ហ៊ុន សែន* ទើបនឹងបានគម្រាមប្ដឹងកាលពីថ្ងៃពុធកន្លងទៅ ដោយបានចោទប្រកាន់មេដឹកនាំគណបក្សប្រឆាំងពីការប្រមាថសភាដែលជាស្ថាប័នកំពូលរបស់ជាតិថាជាសភាយួន, សភាខ្មោច និងសភាចោរ ។

នាយករដ្ឋមន្ត្រីចិត្តឆេវឆាវដូចភ្លើងចំបើងម្នាក់នេះបានស្រែកចំកោងដាក់ក្បាលមីក្រូយ៉ាងដូច្នេះថា "*សភាជាស្ថាប័នខ្ពស់បំផុតរបស់ព្រះរាជាណាចក្រកម្ពុជាដែលកើតចេញពីការបោះឆ្នោតដោយប្រជាជន ហើយត្រូវបានគេប្រមាថថា ជាសភាចោរ, ជាសភាយួន និងជាសភាខ្មោច ។ ហេតុនេះស្ថាប័នប្ដឹងតែម្ដង ឯរឿងដកអភ័យឯកសិទ្ធិអត់ពិបាកទេ* " ។

ទាក់ទិននឹងការគម្រាមរបស់នាយករដ្ឋមន្ត្រី *ហ៊ុន សែន* នេះ ត្រូវបានក្រុមអ្នកតាមដានជាទូទៅលើកឡើងថា លោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ីធ្លាប់បានមានប្រសាសន៍រិះគន់ស្ថាប័នសភាកម្ពុជានេះនៅក្នុងបទសម្ភាសន៍ជាមួយវិទ្យុបារាំងអន្តរជាតិ ។

ទោះជាដូច្នេះក្ដី ក៏លោក *សម រង្ស៊ី* បានបញ្ចេញប្រតិកម្មតបតទៅនឹងការលើកឡើងរបស់លោក *ហ៊ុន សែន* ថា ការគម្រាមប្ដឹងប្រឆាំងមកលើរូបលោកនេះគឺជារឿងនយោបាយដើម្បីបំបិទមាត់ និងបញ្ឈប់សកម្មភាពគណបក្សប្រឆាំង ។ ហើយលោកក៏មិនដែលតក់ស្លុតភ័យខ្លាចនឹងការគម្រាមប្ដឹងបែបនេះទេ ព្រោះលោកធ្លាប់បានទទួលនូវការគម្រាមកំហែងពីសំណាក់អ្នកកាន់អំណាចសព្វថ្ងៃអស់រយៈពេល១៥ឆ្នាំមកហើយ ។

យ៉ាងណាក៏ដោយមេដឹកនាំគណបក្សប្រឆាំង គឺលោក *សម រង្ស៊ី* និងលោក *កឹម សុខា* នៅតែប្រកាន់គោលជំហរធ្វើពហិការប្រជុំសភាលើកដំបូង និងពិធីសច្ចាប្រណិធាន ព្រមទាំងការបោះឆ្នោតជាកញ្ចប់នេះដដែល ទោះបីជាមានការគម្រាមប្ដឹងលោក *សម រង្ស៊ី* ពីសំណាក់នាយករដ្ឋមន្ត្រី *ហ៊ុន សែន* ក៏ដោយ ។

ជាមួយគ្នានេះដែរអគ្គលេខាធិការគណបក្សសិទ្ធិមនុស្សលោក*ញ៉ែមបុញ្ញរិទ្ធ*បានបញ្ចេញប្រតិកម្មថា ការគម្រាមប្ដឹងរបស់លោក *ហ៊ុន សែន* នៅពេលនេះ គឺជាការធ្វើឱ្យមានភាពស្មុគស្មាញកាន់តែធ្ងន់ធ្ងរដល់សេរីភាពនៃការបញ្ចេញមតិ និងស្ថានភាពនយោបាយនៅកម្ពុជាកាន់តែអាប់អួរ ។

លោក *ញ៉ែម បុញ្ញរិទ្ធ* បាននិយាយយ៉ាងដូច្នេះថា "*ខ្ញុំជឿថា ការរិះគន់ការឃោសនាយកមកចោទប្រកាន់ថា ជាការប្រមាថបែបនេះ ។ ហើយការប្ដឹងផ្ដល់អ្នកនយោបាយអញ្ចឹងគឺលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមានលក្ខណៈចង្អៀតចង្អល់ខ្លាំងណាស់ ដែលអាចប៉ះពាល់ដល់អ្នកប្រជាធិបតេយ្យក្នុងការសម្ដែងមតិថែមទៀតផង* " ។

ទន្ទឹមនេះលោកបណ្ឌិត*ឡៅ ម៉ុងហៃ*ដែលជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៃគណៈកម្មការសិទ្ធិមនុស្សអាស៊ីបានធ្វើការឆ្លុះបញ្ចាំងតាមទស្សនៈផ្ទាល់របស់លោកថា បើមានការប្ដឹងមេដឹកនាំគណបក្សប្រឆាំង គឺលោក *សម រង្ស៊ី* មែននោះ វាពិតណាស់ថា តុលាការនៅកម្ពុជាស្ថិតនៅក្រោមឥទ្ធិពលរដ្ឋាភិបាល និងលោក *ហ៊ុន សែន* ។

លោកបណ្ឌិត *ឡៅ ម៉ុងហៃ* បានបញ្ជាក់ច្បាស់ថា "*វាជារឿងមួយមិនល្អទាល់តែសោះព្រោះបើមានការប្ដឹងផ្ដល់អីៗទៅ គឺដូចបង្កើតបញ្ហាឱ្យច្របូកច្របល់ថែមទៀតតែប៉ុណ្ណោះ* " ។

គួរបញ្ជាក់ផងដែរថាខណៈពេលដែលនាយករដ្ឋមន្ត្រីកញ្ចប់ *ហ៊ុន សែន* កំពុងធ្វើការគំរាមកំហែងមកលើលោក *សម រង្ស៊ី* មេដឹកនាំគណបក្សប្រឆាំងនោះ ក៏ស្រាប់តែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) ក៏បានគម្រាមប្ដឹងលោក *សម រង្ស៊ី*ទៅតុលាការផងដែរប្រសិនបើលោកមិនយកប្រាក់ពិន័យចំនួន១០លានរៀលទៅបង់ឱ្យ គ.ជ.ប ទេនោះ ។

លោក*ទេព នីថា* អគ្គលេខាធិការ គ.ជ.ប បានប្រាប់ The Cambodia Daily ថា គ.ជ.ប បានទុកពេល៣០ថ្ងៃដោយគិតតាំងពីថ្ងៃព្រហស្បតិ៍ ទី១៨ ខែកញ្ញា ទៅ ដើម្បីឱ្យលោក *សម រង្ស៊ី* ក៏ដូចជាអ្នកដទៃទៀតមកបង់ប្រាក់ពិន័យពីបទបំពានការធ្វើយុទ្ធនាការរបស់ពួកគេ ។ហើយបើពុំដូច្នោះទេ ពួកគេត្រូវតែប្រឈមនឹងវិធានការតាមផ្លូវច្បាប់ ។

លោក *សម រង្ស៊ី* បានមានប្រសាសន៍ដោយសេចក្ដីក្លាហានថា លោកមិនបានធ្វើអ្វីខុសទេ ហើយក៏មិនបង់ប្រាក់ពិន័យទៅតាមបង្គាប់បញ្ជារបស់ គ.ជ.ប ដែរ ។

លោកបានបញ្ជាក់ច្បាស់ៗថា "*ខ្ញុំមិនបង់ប្រាក់ពិន័យនោះទេ ហើយប្រសិនបើខ្ញុំមានលុយវិញ ខ្ញុំនឹងបរិច្ចាគលុយនោះទៅឱ្យអ្នកក្រីក្ររស់នៅតំបន់អនាធិបតេយ្យ* " ។

ការគម្រាមប្ដឹងដោយនាយករដ្ឋមន្ត្រី*ហ៊ុន សែន*និងអគ្គលេខាធិការគ.ជ.ប បែបនេះត្រូវបានធ្វើឡើងជាបន្តបន្ទាប់គ្នា ខណៈពេលដែលលោក *សម រង្ស៊ី* នៅតែប្រកាន់ជំហរយ៉ាងរឹងមាំថា លោក និងអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងទាំងអស់មិនចូលរួមប្រជុំសភាលើកដំបូង, មិនចូលរួមក្នុងពិធីសច្ចាប្រណិធាន និងមិនចូលរួមបោះឆ្នោតកញ្ចប់ដើម្បីបំពេញមុខលោក *ហ៊ុន សែន* និងគណបក្សប្រជាជនជាដាច់ខាត ។

ប៉ុន្តែលោកបណ្ឌិត *ឡៅ ម៉ុងហៃ* បានព្រមានទុកជាមុនថា ការប្ដឹងមេដឹកនាំគណបក្សប្រឆាំងបែបនេះនឹងនាំឱ្យមានការច្របូកច្របល់ក្នុងប្រទេសកម្ពុជាទៅវិញទេ ពោលគឺមានតែបន្ធូរឥរិយាបថប៉ុណ្ណោះទើបអាចរំលត់អធិករណ៍នេះបានដោយសន្តិវិធី៕

**តមកពីទំព័រ១ ន**

បានរុញសំណុំរឿងប្ដឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ រួចមកក៏ស្រាប់តែត្រូវរ៉ូវគ្នាជាមួយមេដឹកនាំសៀមហើយប្រកាសដកបណ្ដឹងនេះទៅវិញ ។

លោក *សុន ឆ័យ* សមាជិកសភាជាប់ឆ្នោតថ្មីនៃគណបក្សសមរង្ស៊ី និងជាអ្នកនាំពាក្យរបស់គណបក្សបានមានប្រសាសន៍នៅក្នុងបទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី ជុំវិញលទ្ធផលនៃជំនួបរវាងលោកប្រធានបក្ស និងអនុរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកកាលដើមសប្ដាហ៍នេះ ។

ជុំវិញសំនួររបស់វិទ្យុអាស៊ីសេរីលើកឡើងនូវការដែលលោកឧបការី រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកនិយាយអំពីការចង់ឃើញកម្ពុជាសៀមរកដំណោះស្រាយទ្វេភាគីនោះ លោកសុនឆ័យបានអធិប្បាយថា នោះគ្រាន់តែជាសម្ដីថ្លែងក្នុងលក្ខណៈនយោបាយការទូតតែប៉ុណ្ណោះព្រោះសហរដ្ឋអាមេរិកមានផលប្រយោជន៍ជាមួយសៀម ។

ជាបន្ថែមពីលើអ្វីៗជាការចោទសួររបស់វិទ្យុនោះ លោក *សុន ឆ័យ* បានបន្តថ្លែងទៀតថា ការដែលរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* បង្ហាញនូវឥរិយាបថម្ដងរុញ ម្ដងដករឿងប្ដឹងផ្ដល់ទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអាចដោយសារមានមូលហេតុធំពីរ ។

តាមការថ្លែងរបស់លោក *សុន ឆ័យ* ថា "*រដ្ឋាភិបាលលើកបញ្ហានេះទៅប្ដឹងដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ រួចក៏ស្រាប់តែផ្អាកដកបណ្ដឹងនោះវិញ រឿងនេះអាចមានទាក់ទងករណីពីរយ៉ាង ។ ទី១ រដ្ឋាភិបាលកម្ពុជាអាចយល់ថា ការលើកសំណើនេះឡើងមិនអាចឱ្យអង្គការសហប្រជាជាតិពិនិត្យបាននោះទេ ។ ហើយទី២ យើងយល់ថា ប្រហែលជាមានកិច្ចសន្យាអ្វីមួយដែលមេដឹកនាំសៀមបានធ្វើការសន្យាជាមួយមេដឹកនាំកម្ពុជា ហើយក៏មានការចង់ឱ្យមានដំណោះស្រាយឆាប់រហ័ស* " ។

ហេតុផលនៃការដែលរដ្ឋាភិបាល *ហ៊ុន សែន* ម្ដងធ្វើជាប្ដឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ រួចមកគ្រាន់តែនាយករដ្ឋមន្ត្រីសៀមបាននិយាយមក *ហ៊ុន សែន* រួចក៏កម្ពុជាបានដកបណ្ដឹងមកវិញ ហើយឥឡូវថាគ្រោងនឹងប្ដឹងជាថ្មីទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនោះ បញ្ហាអស់នេះបង្កើតជាចម្ងល់ដោយមូលហេតុសមរម្យថា ទំនងជាមានកិច្ចសន្យាសម្ងាត់អ្វីរវាង *ហ៊ុន សែន* និងមេដឹកនាំសៀមនោះ ។

នេះក៏ស្របនឹងហេតុការណ៍ថា*សាម៉ាក់ ស៊ុនដារ៉ាវេត*នាយករដ្ឋមន្ត្រីសៀម បានរងនូវការចោទប្រកាន់ពីក្រុមអ្នកប្រឆាំងសៀមថា គឺជាកូនអុករបស់នាយករដ្ឋមន្ត្រីធ្លាក់ពីអំណាច *ថាក់ស៊ីន* ហើយ *សាម៉ាក់* បានធ្វើសកម្មភាពនយោបាយដើម្បីព្យាយាមបើកផ្លូវឱ្យ *ថាក់ស៊ីន* ឡើងមកកាន់តំណែងនៅប្រទេសសៀមវិញ ។ហើយពិសេសនោះ *សាម៉ាក់* ក៏មានទំនាក់ទំនងជាមួយរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន*ដែល *ហ៊ុន សែន* ខ្លួនឯងបានអួតក្អេងៗកាលប៉ុន្មានខែមុនថា ខ្លួននឹង *ថាក់ស៊ីន* ជាមិត្តភក្តិនឹងគ្នា ហើយបានចុះកិច្ចសន្យានៃរបស់ដែលហៅថាគម្រោងអភិវឌ្ឍន៍តម្លៃទឹកប្រាក់ជាង១ពាន់លានដុល្លារលើដីខ្មែរតំបន់ខេត្តកោះកុង និងតំបន់ប្រាសាទព្រះវិហារ ។

ម្យ៉ាងទៀតថ្មីៗនេះជាពិសេសនៅក្រោយពេលដែលនាយករដ្ឋមន្ត្រីសៀម *សាម៉ាក់* បានរងគំនាបសង្កត់ដោយសាលក្រមរបស់ប្រទេសសៀមបង្គាប់ឱ្យលាលែងពីតំណែងនោះក៏ស្រាប់តែនាយករដ្ឋមន្ត្រីកម្ពុជា *ហ៊ុន សែន* បានប្ដូរចិត្តជាថ្មីថា នឹងលើកយកបញ្ហានេះទៅប្ដឹងនៅអង្គការសហប្រជាជាតិវិញ ។

លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក លោក John Negroponte បានចូលមកបំពេញទស្សនៈកិច្ចផ្លូវការនៅប្រទេសកម្ពុជារយៈពេល៣ថ្ងៃ ពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ខែកញ្ញា ។ក្នុងនោះក៏មានជំនួបរវាងមន្ត្រីជាន់ខ្ពស់សហរដ្ឋអាមេរិកនោះជាមួយនឹងថ្នាក់ដឹកនាំនៃគណបក្សប្រឆាំងផងដែរ ។ អំពីរឿងនេះលោក *សុន ឆ័យ* បានឱ្យដឹងថា ក្នុងអំឡុងជំនួបជាងមួយម៉ោងនោះ មន្ត្រីជាន់ខ្ពស់សហរដ្ឋអាមេរិកនេះចង់ស្ដាប់មតិរបស់មេដឹកនាំគណបក្សប្រឆាំងដើម្បីនឹងយកទៅនិយាយជាមួយនាយករដ្ឋមន្ត្រីកម្ពុជា *ហ៊ុន សែន* ។

ហើយនៅពេលដែលសួរថា តើលោកឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកនិយាយអ្វីខ្លះអំពីបញ្ហាទាក់ទិននឹងជម្លោះខ្មែរសៀមតាមតំបន់ព្រំដែននោះ លោក *សុន ឆ័យ* បានអត្ថាធិប្បាយដោយនិយាយអំពីឥរិយាបថ និងភាសាការទូតរបស់តំណាងសហរដ្ឋអាមេរិក ។

អ្នកនាំពាក្យនៃគណបក្សសមរង្ស៊ីបាននិយាយថា "*ជាគោលការណ៍នោះ សហរដ្ឋអាមេរិកជាមិត្តរបស់សៀមហើយសហរដ្ឋអាមេរិកមានប្រយោជន៍ជាច្រើនពីប្រទេសសៀមយ៉ាងច្រើនលើសលប់ ទាំងផ្នែកសេដ្ឋកិច្ច ក៏ដូចជាផ្នែកនយោបាយ ដែលសហរដ្ឋអាមេរិកមានជាមួយសៀម* " ។

បន្ថែមពីលើនេះ អ្នកនាំពាក្យរបស់គណបក្សសមរង្ស៊ីបានបន្តថាការថ្លែងរបស់លោក John Negroponte ចង់ឃើញកម្ពុជា និងសៀមជជែកគ្នាទ្វេ

**តទៅទំព័រ៣ ន**

**តមកពីទំព័រ១ ក**

**ប៉ុន្តែការថ្លែងរបស់អ្នកនយោបាយជាន់ខ្ពស់គណបក្សប្រជាជនបាន នេះទាក់ទាញនូវប្រតិកម្មរិះគន់ពីគ្រប់មជ្ឈដ្ឋានដែលមានគំនិតចង់ឱ្យប្រទេសជាតិមិនស្ថិតនៅក្រោមអំណាចនៃក្រុមជនផ្ដាច់ការពុករលួយដែលប្រើប្រាស់តួនាទីមុខតំណែងសម្រាប់តែរកប្រយោជន៍របស់ខ្លួន ហើយបង្កើននូវអយុត្តិធម៌សង្គមបង្កើនភាពក្រីក្ររបស់ប្រជារាស្ត្រនោះ ។**

**រឿងនេះមានការរិះគន់ទាំងពីអង្គការសង្គមស៊ីវិលថា រដ្ឋាភិបាលអាណត្តិថ្មីដែលមាន ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ហើយនឹងចេញពីការបោះឆ្នោតកញ្ចប់នៅថ្ងៃទី២៥ ខែកញ្ញា ដែលមានគ្នាដល់ទៅប្រមាណ៣៩៣នាក់នោះ គឺជារដ្ឋាភិបាលដែលសុភាសិតខ្មែរហៅថា *គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ* នោះហើយ ។**

**ចំពោះមុខការកត់សម្គាល់ឃើញដែលមិនមានអ្វីពិបាកយល់ ហើយដែលគណបក្សប្រជាជនក៏រងគំនាបនឹងការរិះគន់ពីសាធារណៈជន និងពីតំណាងនៃអង្គការក្រៅរដ្ឋាភិបាលនានាដែរនោះ លោក ជាម យៀប បានចេញមុខការពារថា នេះមិនមែនជារឿងគ្នាច្រើនអន្សមខ្លោចនោះទេ ។ គាត់បាននិយាយថា ជួនកាលគ្នាច្រើនអាចជួយការងារឱ្យមានទិន្នផលកាន់តែច្រើន កាន់តែល្អ ។**

**ការនិយាយរបស់លោក ជាម យៀប បើពាក្យ *អាច* នេះជាការឆ្លុះបញ្ចាំងបញ្ជាក់ឱ្យដឹងអំពីអារម្មណ៍របស់គាត់ដែលមិនច្បាស់លាស់រួចទៅហើយ អំពីការនឹងមានសមាសភាពរដ្ឋាភិបាលអាណត្តិទី៤យ៉ាងសំពីងសំពោងនោះ ។**

**រដ្ឋាភិបាល នៃប្រទេសកម្ពុជាដ៏តូច និងជាប្រទេសក្រីក្រដែលរស់ពឹងលើជំនួយបរទេសនោះ រដ្ឋាភិបាលមានគ្នាដូចស្រមោច ហើយគណបក្សប្រជាជនគ្រោងបំបែកតំណែងឱ្យច្រើនស្អេកស្កះនោះ វានឹងជួយផ្ដល់ទិន្នផលការងារអ្វីដល់ប្រទេសជាតិ និងប្រជារាស្ត្រខ្មែរ ?**

**និយាយឱ្យស្រួលស្ដាប់ នេះ ជារូបភាពបញ្ជាក់ឱ្យដឹងថា ហ៊ុន សែន មានការគិតខ្វល់ខ្វាយថា បើមិនបំបែកតំណែងកៅអីឱ្យបានច្រើនសម្រាប់បែងចែកបក្ខពួកខ្លួនទេនោះ រដ្ឋាភិបាលរបស់ខ្លួននឹងប្រឈមនឹងសត្រូវ ដ៏ច្រើន ដែលនេះនឹងគម្រាមដល់ប្រព័ន្ធផែនការកាន់អំណាចមួយជីវិត របស់គាត់ ។**

**តាមបទពិសោធន៍នៃរបៀបគ្រប់គ្រងដោយគណបក្សប្រជាជន ហ៊ុន សែន នោះ ការបង្កើនចំនួនមន្ត្រីរដ្ឋាភិបាលអាណត្តិទី៤វាមានន័យថា រដ្ឋាភិបាល ហ៊ុន សែន ថ្មីសំបូរមនុស្សគ្មានសមត្ថភាព ។ ហើយនេះក៏មានន័យផងដែរថា មេដឹកនាំរដ្ឋាភិបាលពោលគឺ ហ៊ុន សែន យល់យ៉ាងច្បាស់អំពីបញ្ហាជម្លោះផ្ទៃក្នុង នៃការបែងចែកតំណែងគ្នាឱ្យបានច្រើន ដូច្នេះក៏បង្កើនជម្លោះ និងចំនួនគូប្រជែងក្នុងបក្ស ម៉្លោះហើយក៏មានការបង្កើនតំណែងឱ្យបានច្រើន មិនខ្វល់ថាវាជាបន្ទុកទម្ងន់ថវិកាជាតិដែលទម្លាក់បន្ថែមឱ្យប្រជារាស្ត្រកាន់តែវេទនានោះទេ ។**

**បែបនេះក៏អាចឱ្យដឹងដែរថា រដ្ឋាភិបាលគ្នាច្រើន ទាំងការងារមានតិច ដែលជាការបង្កើនបន្ទុកចំណាយរបស់រដ្ឋឱ្យថវិកាជាតិកាន់តែយ៉ាប់លំបាកឥតប្រយោជន៍ ហើយមិនបានជួយ អ្វីដល់ប្រជារាស្ត្របន្តិចណានោះ ។**

**រដ្ឋាភិបាលថ្មីដែលមានគ្នាដល់ទៅ៤០០នាក់ ក៏ព្រោះតែនាយករដ្ឋមន្ត្រី ហ៊ុន សែន ខ្លួនឯងគ្មានសមត្ថភាពផង ហើយត្រូវការមនុស្សសម្រាប់តែការលួងចិត្តកុំឱ្យមានប្រតិកម្មរិះគន់ប្រឆាំងនឹងគាត់ផង ហើយក៏ជាការមិនគិតខ្វល់ខ្វាយដល់បន្ទុកថវិកាជាតិ ដែលនិយាយឱ្យខ្លី គឺជារដ្ឋាភិបាលដែលមិនគិតដល់ប្រសិទ្ធភាពនៃការងារបំរើជាតិប្រជារាស្ត្រនោះឡើយ ។**

**នេះក៏ប្រាប់ឱ្យដឹងថា ជាយុទ្ធវិធីនៃការពង្រឹងពង្រីករចនាសម្ព័ន្ធគ្រប់គ្រងរបស់ ហ៊ុន សែន រក្សាការពារអំណាចរបស់ខ្លួនសម្រាប់បំពេញមហិច្ឆតាផែនការអំណាចចង់ធ្វើនាយករដ្ឋមន្ត្រីមួយជីវិតដែលជាប្រឈមទៅនឹងកម្លាំងអំណាចរបស់ប្រជារាស្ត្រនៅថ្ងៃមុខមិនលែងឡើយនោះ៕**